**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីទម្រង់ និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងទម្រង់ លក្ខណៈសម្គាល់ ព័ត៌មាន ការកំណត់សុពលភាព និងការកំណត់អាយុត្រូវផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងគោលបំណងដើម្បីធានាការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឱ្យបានត្រឹមត្រូវ ស្របតាមគោលការណ៍កំណត់នៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សម្រាប់បុគ្គលគ្រប់រូបដែលមានសញ្ជាតិខ្មែរ។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចតទៅ៖

១- **អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ** សំដៅដល់ឯកសារផ្លូវការមួយសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណបុគ្គលទាំងឡាយណាដែលមានសញ្ជាតិខ្មែរ។

២- **ព័ត៌មានជីវមាត្រ** សំដៅដល់ការវាស់ស្ទង់លក្ខណៈជីវសាស្ត្រ និងលក្ខណៈផ្សេងទៀត មានជាអាទិ៍ ស្នាមខ្ចៅដៃ ប្រស្រីភ្នែក មុខ ហត្ថលេខា ឬសំឡេង ដែលអាចប្រមូលបានដោយឌីជីថល និងត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។

៣- **លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ** សំដៅដល់លេខសម្គាល់លើសន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលផ្តល់ឱ្យប្រជាពលរដ្ឋខ្មែរម្នាក់ៗតាមលំដាប់ នៅពេលស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬស្នើសុំផ្តល់ថ្មីឡើងវិញ ក្នុងករណីខូចខាត ឬបាត់បង់ ឬអស់សុពលភាព ឬកែតម្រូវទិន្នន័យ។

៤- **កូដឆ្លើយតបរហ័ស** (QR Code) សំដៅដល់សញ្ញាមានរាងបួនជ្រុង ដែលអាចអានបានដោយឧបករណ៍អេឡិចត្រូនិក ឬទូរសព្ទដៃ ដើម្បីបង្ហាញព័ត៌មានផ្សេងៗ។

៥- **លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល** សំដៅដល់លេខកូដសម្រាប់សម្គាល់របស់បុគ្គលម្នាក់ៗ។ លេខកូដនេះត្រូវបានផ្តល់ជូនបុគ្គលម្នាក់ៗជាអចិន្ត្រៃយ៍ សម្រាប់ប្រើប្រាស់រហូតដល់បុគ្គលនោះទទួលមរណភាព។

៦- **អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា** សំដៅដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលផ្តល់ថ្មីឡើងវិញ ក្នុងករណីអត្តសញ្ញាណបណ្ណនោះមានការខូចខាត ឬបាត់បង់ ឬអស់សុពលភាព ឬកែតម្រូវទិន្នន័យ។

៧- **អត្តសញ្ញាណឌីជីថលបុគ្គល** សំដៅដល់ព័ត៌មានដែលបញ្ជាក់អត្តសញ្ញាណបុគ្គលក្នុងពិភពឌីជីថលដែលព័ត៌មាននេះបានភ្ជាប់ទៅនឹងអត្តសញ្ញាណបុគ្គលក្នុងពិភពពិត។

## ជំពូកទី២
## ទម្រង់ និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

**មាត្រា៤.-**

បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានទម្រង់ជាអេឡិចត្រូនិកសម្រាប់កត់ត្រា រក្សាទុក និងបែងចែកទិន្នន័យបុគ្គល ដែលប្រមូលបាននៅពេលចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាប្រភពទិន្នន័យសម្រាប់បង្កើតអត្តសញ្ញាណឌីជីថលបុគ្គល និងអាចធ្វើអន្តរកម្មជាមួយប្រព័ន្ធផ្សេងទៀតក្នុងទម្រង់ឌីជីថល។

**មាត្រា៥.-**

ព័ត៌មានបុគ្គលក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានដូចខាងក្រោម៖

១- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់សាមីខ្លួន (បើមាន)។

២- លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

៣- ព័ត៌មានជីវប្រវត្តិរបស់សាមីខ្លួន មានដូចខាងក្រោម៖

- នាមត្រកូលនិងនាមខ្លួន
- នាមត្រកូលនិងនាមខ្លួនជាអក្សរឡាតាំង
- ភេទ
- កម្ពស់
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- ស្ថានភាពសញ្ជាតិខ្មែរ (សញ្ជាតិខ្មែរពីកំណើត ឬសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ឬសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម)
- អាសយដ្ឋានបច្ចុប្បន្នរបស់សាមីខ្លួន
- លេខទូរសព្ទទំនាក់ទំនង
- អាសយដ្ឋានអ៊ីមែល (បើមាន)
- ឈ្មោះម្ដាយ និង/ឬឪពុក និងលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់ម្ដាយ និង/ឬឪពុក (បើមាន)
- ព័ត៌មានផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៤- ព័ត៌មានជីវមាត្រ មានដូចខាងក្រោម៖

- រូបថតឌីជីថល
- ស្នាមខ្ទៅដៃ
- ស្នាមស្តែនប្រស្រីភ្នែក (បើមាន)
- ហត្ថលេខាអេឡិចត្រូនិក
- ព័ត៌មានជីវមាត្រផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីព័ត៌មានជីវមាត្រ (ក្រៅពីរូបថតឌីជីថល) របស់បុគ្គលណាម្នាក់មិនអាចធ្វើការចាប់យកបានដោយមូលហេតុពិការភាព ឬមិនគ្រប់គ្រាន់តាមតម្រូវការ នៃស្តង់ដាបច្ចេកទេស ក្រសួងមហាផ្ទៃអាចកំណត់យកព័ត៌មានផ្សេងទៀតមកជំនួសព័ត៌មានជីវមាត្រ ដែលមិនអាចចាប់យកបាន។

៥- ព័ត៌មានអំពីការផ្តល់ និងការគ្រប់គ្រងការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានដូចខាងក្រោម៖

- កាលបរិច្ឆេទដាក់ពាក្យស្នើសុំ
- កាលបរិច្ឆេទផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង
- កាលបរិច្ឆេទផ្តល់ថ្មីឡើងវិញ ដោយមូលហេតុខូចខាត ឬបាត់បង់
- កាលបរិច្ឆេទផ្តល់ថ្មីឡើងវិញ ដោយមូលហេតុកែតម្រូវទិន្នន័យ
- កាលបរិច្ឆេទផ្តល់ថ្មីឡើងវិញ ពេលអស់សុពលភាព
- កាលបរិច្ឆេទមរណភាព
- កាលបរិច្ឆេទបាត់សញ្ជាតិខ្មែរ
- កាលបរិច្ឆេទនៃការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- កាលបរិច្ឆេទអស់សុពលភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ទិន្នន័យផ្សេងទៀត ដើម្បីបម្រើឱ្យការងារគ្រប់គ្រង
- ការចុះនិទ្ទេសផ្សេងៗ។

## ជំពូកទី៣

## ទម្រង់ លក្ខណៈសម្គាល់ ព័ត៌មាន ការកំណត់សុពលភាព និងការកំណត់អាយុត្រូវផ្តល់ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

**មាត្រា៦.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានទម្រង់ជាសន្លឹកប្លាស្ទិក ឬជាតុផ្សំអំពីសារជាតុគីមីសំយោគផ្សេងទៀត និង/ឬជាទម្រង់អេឡិចត្រូនិក។

សន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានលក្ខណៈសម្គាល់ និងសុវត្ថិភាពពិសេស ដោយបង្កប់បន្ទះឈីបអេឡិចត្រូនិក និង/ឬកូដឆ្លើយតបរហ័ស ដែលផ្ទុកព័ត៌មានសំខាន់ៗលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

ទម្រង់ លក្ខណៈសម្គាល់ និងសុវត្ថិភាពពិសេស លើសន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអេឡិចត្រូនិក ជាទិន្នន័យសម្គាល់អត្តសញ្ញាណប្រជាពលរដ្ឋខ្មែរក្នុងទម្រង់ជាអេឡិចត្រូនិក ដែលអាចធ្វើអន្តរកម្មជាមួយប្រព័ន្ធផ្សេងទៀត សម្រាប់សេវាកម្មឌីជីថល។

**មាត្រា៧.-**

ព័ត៌មានបុគ្គលនៅលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានដូចខាងក្រោម៖

១- រូបថតផ្ទៃមុខរបស់សាមីខ្លួន។
២- លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។
៣- នាមត្រកូល និងនាមខ្លួន។
៤- នាមត្រកូល និងនាមខ្លួនជាអក្សរឡាតាំង។
៥- ថ្ងៃខែឆ្នាំកំណើត។
៦- ភេទ។
៧- កម្ពស់។
៨- ទីកន្លែងកំណើត។
៩- អាសយដ្ឋាន។

១០- សុពលភាព (ថ្ងៃផ្តល់ ដល់ថ្ងៃផុតកំណត់)។

១១- ភិនភាគ។

១២- ហត្ថលេខា។

១៣- កូដទិន្នន័យសុវត្ថិភាពដែលអាចអានបានដោយម៉ាស៊ីន ឬឧបករណ៍អេឡិចត្រូនិក។

១៤- ព័ត៌មានផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៨.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវផ្តល់ជូនបុគ្គលមានសញ្ជាតិខ្មែរគ្រប់រូប ដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ។

**មាត្រា៩.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានសុពលភាពប្រើប្រាស់ ដូចខាងក្រោម៖

ក-សុពលភាពរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំពោះបុគ្គលដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ រហូតដល់ក្រោម ៦០ (ហុកសិប) ឆ្នាំ។

ខ-សុពលភាពអចិន្ត្រៃយ៍ គិតចាប់ពីកាលបរិច្ឆេទចេញអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំពោះបុគ្គលដែលមានអាយុចាប់ពី ៦០ (ហុកសិប) ឆ្នាំឡើង។

## ជំពូកទី៤
## អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា

**មាត្រា១០.-**

ពាក្យសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតាត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវភ្ជាប់ឯកសារចាំបាច់មួយចំនួនតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទ និងនីតិវិធីនៃការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១១.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលធ្វើឡើងមុនពេលមានអនុក្រឹត្យនេះ ហើយនៅមានសុពលភាព ត្រូវបន្តប្រើប្រាស់រហូតដល់អស់សុពលភាព។

ក្រោយពេលអនុក្រឹត្យនេះត្រូវបានអនុវត្ត នីតិវិធីណាដែលបានចាប់ផ្តើមហើយដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តចាស់តែមិនទាន់ចប់ ត្រូវបន្តនីតិវិធីដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តចាស់។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលធ្វើឡើងមុនពេលមានអនុក្រឹត្យនេះ ត្រូវបន្តសុពលភាពអនុវត្តដូចនឹងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលបានធ្វើឡើងតាមអនុក្រឹត្យនេះ។

**មាត្រា១៣.-**

អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អនុក្រឹត្យលេខ១៥៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អនុក្រឹត្យលេខ១៣២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា អនុក្រឹត្យលេខ២៧០ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា១ និងមាត្រា៧ នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អនុក្រឹត្យលេខ១៩៨ អនក្រ.បក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា៤ នៃអនុក្រឹត្យលេខ១៣២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីការកែសម្រួលមាត្រា១ថ្មី នៃអនុក្រឹត្យលេខ២៧០ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា១ និងមាត្រា៧ នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៤កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៤៧ អនក្រ.បក
ចុះថ្ងៃទី១ ខែ មេសា ឆ្នាំ២០២៥ ស្តីពីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

## ទម្រង់ លក្ខណៈសម្គាល់ និងសុវត្ថិភាពពិសេស
## លើសន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ







ផ្នែកខាងក្រោយ បង្កប់ **UV**




ផ្នែកខាងក្រោយ ពាសឡាមីណេត